គណបក្ស ភ្លើងទៀន

CANDLELIGHT PARTY

សីលធម៌ សច្ចធម៌ យុត្តិធម៌

លេខ: ១៤៥/២៣ គ.ភ.ទ

**សូមគោរពជូន**

**សម្តេចក្រឡាហោម ស ខេង**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**កម្មវត្ថុ** ៖ សំណើសុំជួប **សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ឬ **តំណាងជាន់ខ្ពស់ក្រសួងមហាផ្ទៃ** ដើម្បីជួយផ្តល់ដំណោះស្រាយពាក់ព័ន្ធឯកសារលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃ របស់គណបក្ស ភ្លើងទៀន។

***សម្តេចក្រឡាហោម ជាទីគោរព,***

**គណបក្ស ភ្លើងទៀន** សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះ **សម្តេចក្រឡាហោម** ដែលបានផ្តល់ការអនុញ្ញាតឲ្យមានជំនួបរវាងតំណាងក្រសួងមហាផ្ទៃ និងតំណាងគណបក្ស ភ្លើងទៀន នាពេលកន្លងមក ដើម្បីរកដំណោះស្រាយសម្រាប់គណបក្ស ភ្លើងទៀន ក្នុងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។

ទោះបីជាគណបក្ស ភ្លើងទៀន ត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចេញសេចក្តីសម្រេចបដិសេធ មិនឲ្យចូលរួមការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នេះក៏ដោយ ក៏គណបក្ស ភ្លើងទៀន នៅតែមានឆន្ទៈក្នុងការចូលរួមការបោះឆ្នោត ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាបន្តបន្ទាប់នៅពេលខាងមុខ។ ប៉ុន្តែដោយសារគណបក្ស ភ្លើងទៀន បានបាត់នូវច្បាប់ដើមនៃប្រកាសលេខ ១៩៣ ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ របស់ក្រសួងមហាផ្ទៃ ស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយ ជាហេតុធ្វើឲ្យគណបក្ស ភ្លើងទៀន នឹងត្រូវប្រឈមការបដិសេធជាថ្មីដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មិនឲ្យចូលរួមការបោះឆ្នោត ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នាអាណត្តិបន្តបន្ទាប់ខាងមុខ។

ដោយហេតុនេះ ថ្នាក់ដឹកនាំគណបក្ស ភ្លើងទៀន មានបំណងជួប **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ឬ **តំណាងជាន់ខ្ពស់ក្រសួងមហាផ្ទៃ** ដើម្បីសុំក្រសួងមហាផ្ទៃ ជួយផ្តល់ដំណោះស្រាយពាក់ព័ន្ធឯកសារលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃ ដើម្បីគណបក្ស ភ្លើងទៀន បានចូលរួមក្នុងការបោះឆ្នោត ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាបន្តបន្ទាប់នៅពេលខាងមុខ។

ថ្នាក់ដឹកនាំគណបក្ស ភ្លើងទៀន ដែលត្រូវសុំជួបជាមួយ **សម្តេចក្រឡាហោម** ឬ **តំណាងជាន់ខ្ពស់ក្រសួងមហាផ្ទៃ** រួមមាន៖

១-លោក **សុក ហាច** អនុប្រធានគណបក្ស

២-លោក **ហុង សុខហួរ** នាយកខុទ្ទកាល័យប្រធានគណបក្ស

ផ្ទះលេខ ៣២០ ផ្លូវលេខ ១០ម៉ែត្រថ្មី បុរីពិភពថ្មី ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
#320, Street 10m Thmey, Borey Piphob Thmey, Bayarb Village, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh
Website: www.candlelightparty.org / Email: info@candlelightparty.org

៣-លោក **គីមសួរ ភិរិទ្ធ** សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស

៤-លោក **ជួន ជួទី** សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស

៥-លោក **ជា ស៊ីណា** នាយករងខុទ្ទកាល័យប្រធានគណបក្ស

៦-លោក **អែម ចន្ថា** សមាជិកគណៈកម្មាធិការនាយកគណបក្ស

ខ្ញុំមានសង្ឃឹម និងជំនឿយ៉ាងមុតមាំថា **សម្តេចក្រឡាហោម** នឹងអនុញ្ញាតឱ្យថ្នាក់ដឹកនាំគណបក្សភ្លើងទៀន បានជួបជាមួយ **សម្តេចក្រឡាហោម** ឬ **តំណាងជាន់ខ្ពស់ក្រសួងមហាផ្ទៃ** ដើម្បីជួយផ្តល់ដំណោះស្រាយពាក់ព័ន្ធឯកសារលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃ របស់គណបក្សភ្លើងទៀន ដោយអនុគ្រោះ។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ៕

ថ្ងៃសុក្រ ០៦រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៣

**ប្រធានគណបក្ស**

**ទាវ វណ្ណុល**